ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សារដ្ឋមន្ត្រី

រ ដ្ឋ ក ម្ពុ ជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខៈ .01.. អនក្រ

ភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២

បានទទួលៈ ថ្ងៃទី 23 ខែ 1 ឆ្នាំ 92 ម៉ោង 10 នាទី ចុះបញ្ជីលេខ 206

# អនុក្រឹត្យ

## ស្តីពីការបង្កើត និង ការគ្រប់គ្រង គ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៤ ក្រ.ប.ក្រប ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៨០ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ប ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីលមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ញា
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៨៥ របស់ក្រុមប្រឹក្សា-រដ្ឋមន្ត្រី ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ

## សំរេច

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១ :** គ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសមានពិរិត :

- ក្រោយសាកលវិទ្យាល័យ
- ឧត្តមសិក្សា
- មធ្យមសិក្សាឯកទេស
- បណ្តុះបណ្តាលកម្មករជំនាញ:
- បឋមសិក្សាឯកទេស

ក្នុងភូមិសិក្សានីមួយ ៗ ខាងលើអាចបង្កើតអោយមានថ្នាក់បណ្តុះបណ្តាល និងស្ត្រីក-ការនានាក្នុងករណីចាំបាច់ ។

**មាត្រា ២ :** គ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស ត្រូវអនុវត្តកម្មវិធីសិក្សាតាមគោលការណ៍អនុកោសល្យ ដោយផ្សារភ្ជាប់ការសិក្សាទ្រឹស្តីជាមួយនឹងការប្រតិបត្តិការអប់រំជាមួយនឹងផលិត-កម្ម អាជីវកម្ម សាលារៀន ថានអោយធានាកា ។

# ជំពូកទី២

## ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

**មាត្រា ៣ :** ក្រសួងអប់រំមានសិទ្ធិស្នើសុំបង្កើតគ្រឹះស្ថានឧត្តមសិក្សាថ្មី ។

- ស្ថាប័ន ក្រសួង និង គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងមានសិទ្ធិស្នើសុំបង្កើតគ្រឹះស្ថានមធ្យមសិក្សាឯកទេស និង គ្រឹះស្ថានសិក្សាដែលមានបណ្ដុះបណ្ដាលកម្រិតកម្មករ-ជំនាញ និង កម្រិតបឋមសិក្សាឯកទេស ។

- បុគ្គល ឬ សមូហភាព ឬ ក្រុមហ៊ុនឯកជន មានសិទ្ធិស្នើសុំបង្កើតថ្នាក់ ឬសាលាមធ្យមសិក្សាឯកទេសឯកជន ថ្នាក់ ឬ សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈឯកជន ។

ក្រសួងអប់រំ មានភារកិច្ចធ្វើលិខិតបទដ្ឋានមួយដោយឡែក ស្ដីពីការគ្រប់គ្រងថ្នាក់ ឬ សាលាមធ្យមសិក្សាឯកទេសឯកជន ថ្នាក់ ឬ សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈឯកជននេះ ។

**មាត្រា ៤ :** បែបបទបង្កើតគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសមានដូចតទៅ :-

- ចំពោះគ្រឹះស្ថានសិក្សា ឬ ថ្នាក់ដែលបណ្ដុះបណ្ដាលកម្រិតក្រោយសាកលវិទ្យាល័យកម្រិតឧត្តមសិក្សា ឬ កម្រិតមធ្យមសិក្សាឯកទេសរដ្ឋ និង ឯកជន ស្ថាប័នក្រុមហ៊ុនសមូហភាព បុគ្គលដែលស្នើសុំបង្កើត ត្រូវរៀបចំសំណុំលិខិតដែលពាក់ព័ន្ធក្នុងការស្នើសុំបង្កើតគ្រឹះស្ថានសិក្សា ឬ ថ្នាក់នោះ ផ្ញើជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីពិនិត្យសម្រេច និង ចម្លងជូនខុទ្ទកាល័យក្រុម-ប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ និង ក្រសួងអប់រំ ។ ផ្អែកលើយោបល់របស់ស្ថាប័នទាំងពីរ ក្រុមប្រឹក្សារដ្ឋមន្ត្រីនឹងចេញសេចក្ដីសម្រេចបង្កើត ។

- ចំពោះគ្រឹះស្ថានសិក្សា ឬ ថ្នាក់ដែលបណ្ដុះបណ្ដាលកម្មករជំនាញ ឬកម្រិតបឋមសិក្សាឯកទេស ឬ ថ្នាក់ហ្វឹកការ ឬ ថ្នាក់បណ្ដុះបណ្ដាលរយៈពេលខ្លី ស្ថាប័ន អង្គភាពដែលស្នើសុំបង្កើត ត្រូវរៀបចំសំណុំលិខិតផ្ញើជូនក្រសួងផែនការ និង ក្រសួងអប់រំ ។ ក្រោយពេលដែលក្រសួងទាំងពីរនេះបានពិភាក្សាគ្នាយល់ព្រមហើយ ក្រសួងអប់រំឆ្លើយទៅស្ថាប័ន អង្គភាពដែលស្នើសុំ-បង្កើតគ្រឹះស្ថានសិក្សា ឬ ថ្នាក់នោះ ដោយចេញសេចក្ដីសម្រេចបង្កើត ។

- ចំពោះសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈឯកជន បុគ្គល ឬ សមូហភាព ឬ ក្រុមហ៊ុនឯកជនដែលមានបំណងចង់បង្កើត ត្រូវរៀបចំសំណុំលិខិតផ្ញើជូនក្រសួងអប់រំ ដើម្បីពិនិត្យ សម្រេច និង ចម្លងជូនក្រសួងផែនការ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងដែលសាលានោះតាំងនៅ ។ ផ្អែកលើយោបល់យល់ព្រមរបស់ក្រសួងផែនការ និង គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ក្រសួងអប់រំនឹងចេញសេចក្ដីសម្រេចបង្កើត ។

- ចំពោះថ្នាក់ហ្វឹកហ្វឺនមុខរបរឯកជនដែលមានរយៈពេលសិក្សាតិចជាងមួយឆ្នាំ គណៈ-កម្មាធិការប្រជាជនខេត្ត-ក្រុង មានភារកិច្ចពិនិត្យ និង ចេញសេចក្ដីសម្រេចបង្កើត ។

**មាត្រា ៥ :** - ការបិទគ្រឹះស្ថានសិក្សា ការរំលាយគ្រឹះស្ថានសិក្សាបញ្ចូលគ្នា ការបំបែកគ្រឹះ-ស្ថានសិក្សាមួយអោយចេញជាគ្រឹះស្ថានសិក្សាច្រើន ត្រូវគោរពតាមលក្ខការណ៍ដូចមានចែងក្នុងមាត្រា ៤ ។

- ការបិទមុខជំនាញដែលមានហើយ ការបង្កើតមុខជំនាញថ្មី ការបើកការសិក្សាពេលល្ងាច និងការសិក្សាតាមលិខិត ការសិក្សាពិសេសនានា ពេលថ្ងៃនៅក្នុងគ្រឹះស្ថានឧត្តម-សិក្សា និងសិក្សាឯកទេសរដ្ឋ ឬ ឯកជន ត្រូវបានស្នើឡើងតាមលិខិតរបស់ស្ថាប័នក្រុមហ៊ុន សមូហភាព- បុគ្គលដែលមានគ្រឹះស្ថានសិក្សាទៅក្រសួងផែនការ និង ក្រសួងអប់រំ ។ ក្រោយពីបានពិភាក្សាជាមួយក្រសួងផែនការលើសំណើខាងលើ ក្រសួងអប់រំត្រូវឆ្លើយទៅស្ថាប័ននោះវិញ ។

- ការបិទមុខវិជ្ជាជីវៈដែលមានហើយ ការបើកមុខវិជ្ជាជីវៈថ្មីនៅថ្នាក់ ឬ នៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន បុគ្គល ឬ សមូហភាព ឬក្រុមហ៊ុនឯកជនដែលជាម្ចាស់ ត្រូវធ្វើសំណើទៅគណៈកម្មាធិការប្រជាជនខេត្ត-ក្រុងដែលសាលា ឬ ថ្នាក់នោះតាំងនៅដើម្បីពិនិត្យ និង សំរេច ។

មាត្រា ៦ : សំណុំលិខិត ស្តីពីការបង្កើតគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេសមាន :-

១- លិខិតស្នើសុំការអនុញ្ញាតបង្កើតដោយមានបញ្ជាក់ពីគោលបំណង និងទិសដៅនៃការបណ្តុះបណ្តាល ។

២- របាយការណ៍រៀបរាប់ពីចំណុច ៣ ដូចតទៅ :

- គំរោងផែនការសិក្សាកម្មវិធីបណ្តុះបណ្តាល កំរិតវប្បធម៌ និងចំនួនសិស្ស ឬ និស្សិតដែលត្រូវជ្រើសរើសក្នុងឆ្នាំនីមួយៗ ។

- ស្ថានភាពបច្ចុប្បន្ននៃកម្មាភិបាល បុគ្គលិក គ្រូបង្រៀន ទីកន្លែងអាគារ សំភារៈបរិក្ខារដែលមានហើយ ។

- កសាងរចនាសម្ព័ន្ធចាត់តាំង តំរូវការសំភារៈបរិក្ខារបច្ចេកទេស ដើម្បីកសាងមូលដ្ឋានសំភារៈ តម្រូវការកម្មាភិបាល បុគ្គលិកសិក្សា ។

៣- គំរោងសេចក្តីសំរេច ស្តីពីការបង្កើតគ្រឹះស្ថានសិក្សា ឬ ថ្នាក់បណ្តុះបណ្តាល ។ ចំពោះថ្នាក់ ឬ សាលាមធ្យមសិក្សាឯកទេសឯកជន ថ្នាក់ ឬ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន វាក្យខ័ណ្ឌទី ៣ នៃចំណុច ២ មិនចាំបាច់ធ្វើបញ្ជាក់ក្នុងរបាយការណ៍ទេ ។

មាត្រា ៧ : គ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសមានភារកិច្ចទទួលខុសត្រូវបណ្តុះបណ្តាលបញ្ញវ័ន្ត អ្នកបច្ចេកទេស និង កម្មករ ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រទេសជាតិ ។ ចំនួននៃការជ្រើសរើសសិស្ស និស្សិតអោយចូលរៀនក្នុងគ្រឹះស្ថានសិក្សារដ្ឋនឹងត្រូវកំនត់ជារៀងរាល់ឆ្នាំ អាស្រ័យទៅលើលទ្ធភាពរបស់គ្រឹះស្ថានសិក្សានីមួយៗ ។

មាត្រា ៨ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ និង ក្រសួងអប់រំ ត្រូវរួមគ្នាពិភាក្សាជាមួយស្ថាប័ន ក្រុមហ៊ុន សមូហភាព បុគ្គល សាមី លើគោលបំណងបើកគ្រឹះស្ថានសិក្សាឯកទេស ឬ ថ្នាក់បណ្តុះបណ្តាល លើទិសដៅបណ្តុះបណ្តាល លើតម្រូវការកម្មាភិបាល លើការចាត់តាំង និង លើអង្គការលេខនៃគ្រឹះស្ថានសិក្សាឯកទេស ឬ ថ្នាក់បណ្តុះបណ្តាលនោះ ។ ក្រសួងផែនការត្រូវសិក្សាពិនិត្យអំពីតម្រូវការចាំបាច់នៃប្រទេសជាតិ ។ ក្រសួងអប់រំមានភារកិច្ចពិនិត្យ និង សំរេចលើទិសដៅគោលការ វិធីបណ្តុះបណ្តាល ផែនការសិក្សា កម្មវិធីសិក្សា និង ពិនិត្យ

លក្ខការណ៍ផ្សេង ៗ ដើម្បីធានាគុណភាពបណ្តុះបណ្តាល " ការចាត់តាំងគ្រប់គ្រងគ្រឹះ-ស្ថានសិក្សា គណៈគ្រប់គ្រងជួរបុគ្គលិកសិក្សា និង សំភារៈបរិក្ខារបច្ចេកទេស " ។

ក្រសួងអប់រំ ត្រូវរៀបចំការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធខាងលើ ដើម្បីរកមតិយោបល់អោយបានឯកភាពគ្នា រួចក្រសួងអប់រំត្រូវរាយការណ៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រីពិនិត្យ និង សំរេចជាចុងក្រោយ ឬ ត្រូវឆ្លើយតបទៅស្ថាប័ន ក្រុមហ៊ុន សមូហភាព បុគ្គលណាមួយ ដែលស្នើស្របតាមករណីដែលមានចែងក្នុងមាត្រា ៤ និង មាត្រា ៥ ។ ក្នុងករណីដែលមានមតិមិនឯកភាពគ្នានោះ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ និង ក្រសួងអប់រំ ត្រូវធ្វើរបាយការណ៍ដោយឡែក ៗ ផ្ញើជូនក្រុមប្រឹក្សារដ្ឋមន្ត្រី សំរេច។

## ជំពូកទី ៣

### ភារកិច្ចនិងកំរិតបណ្តុះបណ្តាលរបស់គ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

មាត្រា ៩ : គ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស មានភារកិច្ចជាមូលដ្ឋាន ២ គឺ :

ទី ១ : បណ្តុះបណ្តាល និងលុក្រឹតការ បញ្ញាវ័ន្ត និងអ្នកបច្ចេកទេសអោយធានាបានគុណភាពតាមទិសដៅនៃគ្រឹះស្ថានសិក្សានីមួយ ៗ ។

ទី ២ : ចាត់តាំងការងារស្រាវជ្រាវ និង ផ្សព្វផ្សាយបច្ចេកទេសវិទ្យា-សាស្ត្រ ការងារផលិតកម្ម និង អាជីវកម្មនៅក្នុងគ្រឹះស្ថានសិក្សា ដើម្បីពង្រឹងតួនាទីរបស់គ្រឹះស្ថានសិក្សានោះ អោយក្លាយទៅជាមជ្ឈមណ្ឌលវប្បធម៌ វិទ្យាសាស្ត្រ និង បច្ចេកទេស ។

ស្តីការងារអាជីវកម្ម និង ផលិតកម្ម គ្រឹះស្ថានសិក្សានីមួយ ៗ អាចចុះកិច្ចព្រមព្រៀងជាមួយរោងចក្រ សហគ្រាសក្រុមហ៊ុនរដ្ឋ ឬ ឯកជនដោយមានការឯកភាពពីក្រសួង ឬ ស្ថាប័នជាអ្នកគ្រប់គ្រង ។

មាត្រា១០ : ~~ការបណ្តុះបណ្តាលទៀងទាត់ " បណ្តុះបណ្តាល~~រយៈពេលវែង " កំរិត និងរយៈពេលបណ្តុះបណ្តាល ត្រូវកំណត់ដូចត.ទៅ :

- កំរិតក្រោយសាកលវិទ្យាល័យ

ជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានសញ្ញាប័ត្រឧត្តមសិក្សា បណ្តុះបណ្តាលថ្នាក់បណ្ឌិត មានរយៈពេលសិក្សា និង ស្រាវជ្រាវពី ៣ ឆ្នាំទៅ ៥ ឆ្នាំ ។

- កំរិតឧត្តមសិក្សា

ជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំណេះទូទៅ បំពេញវិជ្ជា ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ ។ រយៈពេលបណ្តុះបណ្តាលមានពី ៤ ឆ្នាំទៅ ៧ ឆ្នាំ ស្រេចទៅតាមមុខជំនាញ ដោយមិនគិតថ្នាក់ត្រៀម ។

- <u>កំរិតមធ្យមសិក្សាឯកទេស</u>

ជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានកំរិតវប្បធម៌ជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំណេះទូទៅ ឬ បំពេញវិជ្ជា ឬ សញ្ញាប័ត្រដែលមានតម្លៃស្មើ ។ រយៈពេលបណ្តុះបណ្តាលមានពី ២ ឆ្នាំ ទៅ ៤ ឆ្នាំកន្លះ ផ្អែកទៅតាមមុខជំនាញ ។

- <u>កំរិតបណ្តុះបណ្តាលវិជ្ជាជីវៈ</u>

ជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ចំណេះទូទៅ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ ។ រយៈពេលបណ្តុះបណ្តាលមានពី ១ ឆ្នាំទៅ ២ ឆ្នាំ ។

- <u>កំរិតបឋមសិក្សាឯកទេស</u> :

ជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានកំរិតវប្បធម៌ជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ចំណេះទូទៅ ឬ បំពេញវិជ្ជា ។ រយៈពេលបណ្តុះបណ្តាល ៦ ខែ ទៅ ១ ឆ្នាំ ។

ដោយឡែកចំពោះមុខជំនាញដែលទាមទារទេពកោសល្យរបស់បេក្ខជន ក្រសួងអប់រំ ត្រូវពិភាក្សាជាមួយស្ថាប័នដែលមានគ្រឹះស្ថានសិក្សានោះ ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស និង កំណត់រយៈពេលបណ្តុះបណ្តាល ដោយផ្អែកទៅលើកំរិត និងរយៈពេលបណ្តុះបណ្តាលខាងលើ ។

ចំពោះការងារបណ្តុះបណ្តាលកម្មាភិបាល បុគ្គលិក និង កម្មករសំរាប់ខេត្តព្រៃភ្នំដាច់ស្រយាល ការបណ្តុះបណ្តាលចំពោះជនជាតិភាគតិច ត្រូវរៀបចំអោយមានការអនុគ្រោះចំពោះកំរិតវប្បធម៌ក្នុងការជ្រើសរើស និង កំណត់រយៈពេលបណ្តុះបណ្តាលអោយសមស្របតាមសភាពការណ៍ជាក់ស្តែងរបស់ខេត្តទាំងនោះ ។

ក្រសួងអប់រំ ត្រូវធ្វើការណែនាំអោយបានច្បាស់លាស់ចំពោះបញ្ហានេះ ។

<u>មាត្រា ១១</u> : ទន្ទឹមនឹងការបណ្តុះបណ្តាលទៀងទាត់ចំពោះមុខនេះ គ្រឹះស្ថានសិក្សាឯកទេសអាចបើកថ្នាក់បណ្តុះបណ្តាលរយៈពេលខ្លី <u>ដោយអនុវត្តតាមចំណុចខាងក្រោមនេះ</u> :-

- ការបណ្តុះបណ្តាលបំពេញកំរិតឧត្តមសិក្សា ឬ មធ្យមសិក្សាឯកទេស អាចបង្កើតអោយមានឡើងចំពោះកម្មាភិបាលដែលមានទុនសមត្ថភាពក្នុងមុខជំនាញ និង បានបំរើការងារក្នុងមុខជំនាញនោះមួយរយៈពេលហើយ និង បញ្ជូនអោយទៅរៀនក្នុងមុខជំនាញដដែល ។ រយៈពេលបណ្តុះបណ្តាលអាចបំពេញអោយខ្លីជាងរយៈពេលបណ្តុះបណ្តាលទៀងទាត់ ដែលមានកំណត់ក្នុងមាត្រា ១០ ប៉ុន្តែត្រូវរក្សាខ្លឹមសារនៃការបណ្តុះបណ្តាលអោយចប់កម្មវិធី ដូចជាខ្លឹមសារនៃការបណ្តុះបណ្តាលទៀងទាត់ដែរ ។ នៅពេលប្រលងបញ្ចប់ការសិក្សាជាប់ និស្សិតជាកម្មាភិបាលទាំងនោះ នឹងបានទទួលសញ្ញាប័ត្រស្របតាមកំរិតបណ្តុះបណ្តាលរបស់ខ្លួន ។

- ការបណ្តុះបណ្តាលក្នុងរយៈពេលតិចជាង ១ ឆ្នាំ ក្នុងន័យចាក់បំប៉នចំណេះដឹងលើមុខជំនាញ ដើម្បីអោយកម្មាភិបាល បុគ្គលិក កំរិតបឋម និង កម្មករជំនាញ ដែលមានកំរិតមុខជំនាញនៅទាបមានសញ្ញាណជាមូលដ្ឋានខ្លះៗ ក្នុងមុខជំនាញអាចធ្វើការបាន នឹងត្រូវបង្កើតអោយមានឡើងសំរាប់បំពេញសេចក្តីត្រូវការ ឬ សំរាប់លើកកំពស់ការងារអោយកាន់តែមានប្រសិទ្ធ-

មាត្រា ១២ ៖ - ទន្ទឹមនឹងការបណ្ដុះបណ្ដាលទៀងទាត់នៅក្នុងគ្រឹះស្ថានសិក្សានីមួយៗ នៅមានថ្នាក់បណ្ដុះបណ្ដាលសំរាប់កម្មាភិបាល បុគ្គលិក កម្មករ ដោយមិនបាច់បោះបង់ការងាររបស់ខ្លួនតាមរូបភាពការសិក្សាពេលល្ងាច និងការសិក្សាតាមលិខិត ។ កម្មវិធីសិក្សាសំរាប់ថ្នាក់បណ្ដុះបណ្ដាលប្រភេទនេះ ត្រូវធានានាខ្លឹមសារ និងគុណភាពបណ្ដុះបណ្ដាលអោយដូចជាការបណ្ដុះបណ្ដាលទៀងទាត់ដែលមានចែងក្នុងមាត្រា ១០ ដោយបន្ថយរយៈពេលបណ្ដុះបណ្ដាល ។ ក្រសួងអប់រំត្រូវមានវិធានការពង្រីកអោយបាននូវប្រព័ន្ធថ្នាក់បណ្ដុះបណ្ដាលនេះ និងត្រូវធានានាគុណភាពបណ្ដុះបណ្ដាល ។ ការបណ្ដុះបណ្ដាលប្រភេទនេះ ត្រូវបានទទួលបញ្ញាប័ត្រជាផ្លូវការដូចការបណ្ដុះបណ្ដាលទៀងទាត់ដែរ ។

មាត្រា ១៣ ៖ - ផែនការសិក្សា និងកម្មវិធីសិក្សាសំរាប់កំរិតបណ្ដុះបណ្ដាលទៀងទាត់នីមួយៗ ត្រូវតាក់តែងអោយមានចំណុចសំខាន់ ទាំង ៥ ខាងក្រោមនេះ ៖-

- កម្មវិធីវប្បធម៌ទូទៅ
- កម្មវិធីអប់រំកាយកីឡា
- កម្មវិធីចំណេះដឹងវិទ្យាសាស្ត្រមូលដ្ឋាន
- កម្មវិធីទ្រឹស្ដីមុខជំនាញបច្ចេកទេស
- កម្មវិធីសិក្សាប្រតិបត្តិ កម្មសិក្សា និងការចូលរួមធ្វើពលកម្ម ផលិតកម្ម ។

ក្រសួងអប់រំ ត្រូវធ្វើបារាចរណែនាំអនុវត្តចំណុចទាំង ៥ ខាងលើគ្រប់គ្រឹះស្ថានឧត្តមសិក្សា និងសិក្សាបច្ចេកទេសអោយស្របតាមកំរិតបណ្ដុះបណ្ដាលនីមួយ ៗ ។

កម្មវិធីវប្បធម៌ទូទៅ និងអប់រំកាយកីឡា នឹងកំណត់ដោយក្រសួងអប់រំ

ចំពោះកំរិតឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេស ចាំបាច់ត្រូវរៀនភាសាបរទេសណាមួយជាវិជ្ជាភាសា ។

មាត្រា ១៤ ៖ - ក្រៅអំពីការងារប្រតិបត្តិនៅក្នុងបន្ទប់ពិសោធន៍ និងរោងជាងនៅក្នុងសាលាគ្រឹះស្ថានឧត្តមសិក្សា ~~និងសិក្សាបច្ចេកទេសទាំងអស់ ត្រូវមានផែនការបញ្ជូ~~ននិស្សិត និស្សិតអោយទៅធ្វើកម្មសិក្សានៅតាមអង្គភាពនានា ។ អង្គភាពទាំងនោះត្រូវមានភារកិច្ចទទួលសិស្ស និស្សិតឯកទេសបង្កលក្ខណៈងាយស្រួលអោយសិស្ស និស្សិតបានអនុវត្តជាក់ស្ដែង ជួយឧបត្ថម្ភជាសំភារៈ និង មធ្យោបាយផ្សេងៗ ក្នុងរយៈពេលដែលសិស្ស និស្សិតធ្វើកម្មសិក្សាក្នុងអង្គភាពខ្លួន និង ជួយគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាបច្ចេកទេសក្នុងការអនុវត្តផែនការនៃកម្មសិក្សានោះ អោយបានជោគជ័យ ។ ទន្ទឹមនឹងនេះ គ្រឹះស្ថានសិក្សាត្រូវលើកការជួយស្រាវជ្រាវវិភាគពិសោធ តាមសំណើរបស់ក្រសួងដែលពាក់ព័ន្ធ ។

## ជំពូកទី ៤

## ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាបច្ចេកទេស

មាត្រា ១៥ ៖ សាកលវិទ្យាល័យត្រូវមានថវិកាស្វ័យភាព និងមានឋានៈជាមូលដ្ឋានថ្នាក់ទី ១ ។

- គ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេសរដ្ឋ និងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈរដ្ឋ សាលាបឋម-សិក្សាបច្ចេកទេសរដ្ឋ ត្រូវមាន [illegible]

របស់ក្រសួង ឬ ស្ថាប័នដែលគ្រប់គ្រងគ្រឹះស្ថានសិក្សានោះ ។

<u>មាត្រា ១៦</u> : - គ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេសនីមួយៗ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងមួយ ឬ ច្រើនរូប ។

- នាយកសាកលវិទ្យាល័យកំណត់នាមថា " សាកលវិទ្យាធិការ " មានឋានៈស្មើអនុរដ្ឋមន្ត្រី ។

- នាយករងសាកលវិទ្យាល័យកំណត់នាមថា " សាកលវិទ្យាធិការរង " ត្រូវតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ។

- នាយក នាយករងមហាវិទ្យាល័យជំនួសសាកលវិទ្យាល័យកំណត់នាមថា " ព្រឹទ្ធសាស្ត្រាចារ្យ - ព្រឹទ្ធសាស្ត្រាចារ្យរង " ត្រូវតែងតាំងដោយប្រធានស្ថាប័នដែលគ្រប់គ្រងសាកលវិទ្យាល័យ ។

- នាយក នាយករងគ្រឹះស្ថានមធ្យមសិក្សាឯកទេស បឋមសិក្សាឯកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវតែងតាំងដោយប្រធានស្ថាប័នដែលគ្រប់គ្រងគ្រឹះស្ថានសិក្សានោះ ។

- នាយក នាយករងសាលា ឬ ផ្នាក់មធ្យមសិក្សាឯកទេសឯកជន សាលា ឬផ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈឯកជន ត្រូវមានសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងអប់រំ ។

ក្រសួងអប់រំមានភារកិច្ចរៀបចំលិខិតបទដ្ឋានមួយស្តីពីសិទ្ធិអំណាច និងភារកិច្ចនាយក នាយករងគ្រប់គ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស ។

<u>មាត្រា ១៧</u> : - ការជ្រើសរើសនិស្សិតអោយចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស ត្រូវគោរពតាមបទបញ្ជាជ្រើសរើសដែលក្រសួងអប់រំបានកំណត់ ។ សិស្សមានសញ្ញាប័ត្រមធ្យមសិក្សាភូមិ ២ ចំណេះទូទៅ ឬបំពេញវិជ្ជា ឬសញ្ញាប័ត្រដែលមានតម្លៃស្មើចង់បន្តការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា ត្រូវដាក់ពាក្យចូលរៀនថ្នាក់ត្រៀមឧត្តមសិក្សាជាមុនសិន ។

<u>មាត្រា ១៨</u> : - គ្រឹះស្ថានឧត្តមសិ~~ក្សា និង និស្សិតឯកទេសទាំងអស់ត្រូវមានតាំង~~ដោយមានការប្រឡងបញ្ចប់ការសិក្សាស្របទៅតាមបទបញ្ជារបស់ក្រសួងអប់រំ ។ សិស្ស និស្សិតនឹងអាចទទួលយកសញ្ញាប័ត្រដែលខ្លួនប្រឡងជាប់ ក្នុងពិធីប្រគល់សញ្ញាប័ត្រដែលបានប្រព្រឹត្តធ្វើក្រោយពីការប្រកាសលទ្ធផលប្រឡងយ៉ាងយូរបំផុតមួយខែ ។ សញ្ញាប័ត្រទាំងឡាយដែលត្រូវចេញអោយសិស្ស និស្សិតត្រូវគោរពតាមគំរូដែលក្រសួងអប់រំបានកំណត់ ។ ស្ថាប័នដែលមានគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសនៅក្រោមឱវាទមានភារកិច្ចរៀបចំស្នើព្រមស្មើលទ្ធផលដែលសិស្ស និស្សិតបានប្រឡងជាប់សញ្ញាប័ត្រតាមសំណើរបស់ថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា ។

លើសពីមូលដ្ឋាននៃសេចក្តីសំរេចនោះ សញ្ញាប័ត្រទាំងឡាយត្រូវចុះហត្ថលេខាដោយថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា និងមានសេចក្តីបញ្ជាក់ពីថ្នាក់ដឹកនាំស្ថាប័នដែលគ្រប់គ្រងគ្រឹះស្ថានសិក្សា ដោយមានចុះហត្ថលេខានិងបោះត្រានៃស្ថាប័ននោះ ។

ក្រសួងអប់រំមានភារកិច្ចធ្វើលិខិតបទដ្ឋានដោយឡែកស្ដីពីការចេញវិញ្ញាបនប័ត្រ និង សញ្ញាប័ត្រនៅថ្នាក់សាលា ឬ ថ្នាក់មធ្យមសិក្សាឯកទេសឯកជន និងសាលា ឬថ្នាក់បណ្ដុះ-បណ្ដាលវិជ្ជាជីវៈឯកជន ។

<u>មាត្រា ១៩ :</u> - អ្នកជាប់សញ្ញាប័ត្រឧត្ដមសិក្សា និងសិក្សាឯកទេសនឹងអាចទទួលការងារធ្វើដោយផ្អែកលើសេចក្ដីត្រូវការរបស់រដ្ឋ និង សង្គម ។

ក្រសួងផែនការមានភារកិច្ចរៀបចំលិខិតបទដ្ឋានមួយស្ដីពីការប្រើប្រាស់អ្នកជាប់សញ្ញាប័ត្រឧត្ដមសិក្សា និង សិក្សាឯកទេស ។

<u>មាត្រា ២០ :</u> - ក្រសួង ស្ថាប័នថ្នាក់ស្មើក្រសួង និង គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងដែលមានគ្រឹះស្ថានឧត្ដមសិក្សា និង សិក្សាឯកទេសនៅក្រោមឱវាទមានភារកិច្ចគ្រប់គ្រងដឹកនាំគ្រឹះស្ថានសិក្សាទាំងនោះ លើគ្រប់សកម្មភាពខ្លឹមសារ និង វិធីបណ្ដុះបណ្ដាលចំពោះកម្មាភិបាល បុគ្គលិក សិស្ស និស្សិត អង្គការលេខដូរបុគ្គលិកសិក្សា ថវិកា ទ្រព្យធានសម្ភារៈ និង បច្ចេកទេស គុណភាពបណ្ដុះបណ្ដាល ។ល។

<u>មាត្រា ២១ :</u> - ក្រសួងអប់រំត្រូវទទួលខុសត្រូវ :

- រៀបចំគំរោងបទបញ្ជាផ្សេងៗ សំរាប់អនុវត្តនៅតាមគ្រឹះស្ថានសិក្សានានា ផ្ញើជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីសុំការឯកភាព ។
- ត្រួតពិនិត្យការអនុវត្តបទបញ្ជាផ្សេងៗ នៅក្នុងគ្រឹះស្ថានសិក្សានីមួយៗ ។
- ផ្ដល់ការណែនាំ ការតំរង់ទិសនៅគ្រប់ស្ថាប័នដែលមានគ្រឹះស្ថានសិក្សាក្នុងការអនុវត្តគោលនយោបាយទូទៅស្ដីពីឧត្ដមសិក្សា និង សិក្សាឯកទេស ។
- ជួយឧបត្ថម្ភស្ថាប័នដែលមានគ្រឹះស្ថានសិក្សានៅក្រោមឱវាទក្នុងការធ្វើផែនការសិក្សា កម្មវិធីសិក្សា មុខវិជ្ជានានា និពន្ធ និងបោះពុម្ពសៀវភៅសិក្សា ការបណ្ដុះបណ្ដាល និងសុក្រឹតការជូរកម្មាភិបាលគ្រប់គ្រងគ្រឹះស្ថានសិក្សា និង ជូរបុគ្គលិកសិក្សា ហើយនៅទីបញ្ចប់គឺ ការត្រួតពិនិត្យលើការអនុវត្ត ។
- រៀបចំបង្កើតបទបញ្ជា ស្ដីពីការងារបណ្ដុះបណ្ដាល ស្ដីពីលក្ខណៈកំណត់គុណភាពបណ្ដុះ-បណ្ដាលនៅតាមគ្រឹះស្ថានឧត្ដមសិក្សា និង សិក្សាឯកទេស ។
- ជួយណែនាំលើការអនុវត្តការងារ និង ធ្វើអធិការកិច្ចនៅតាមគ្រឹះស្ថានសិក្សា ។

## <u>ជំពូកទី៥</u>

## <u>អវសានបញ្ញត្តិ :</u>

<u>មាត្រា ២២ :</u> - គ្រឹះស្ថានឧត្ដមសិក្សា និង សិក្សាឯកទេសដែលមានរួចមកហើយតាមសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ឬ ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវរាយការណ៍ទៅក្រសួងអប់រំ អំពីស្ថានភាពបច្ចុប្បន្នរបស់ខ្លួន ៖ របនាសម្ព័ន្ធ មុខជំនាញ ចំនួនសិស្ស និស្សិត អង្គការ-លេខដូរបុគ្គលិកសិក្សា ផែនការសិក្សា លទ្ធផលនៃការបណ្ដុះបណ្ដាលក្នុងឆ្នាំកន្លងទៅ និងផែន-ការឆ្នាំអនាគត ៖ ។

<u>មាត្រា ២៣</u> : - អនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៨៤ និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>មាត្រា ២៤</u> : - រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងអប់រំ / រដ្ឋមន្ត្រីនៃបណ្តាក្រសួងដែលមានការពាក់ព័ន្ធ និង គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងទាំងអស់ដែលមានគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
  ៖ "<u>ដើម្បីជ្រាបជាពត៌មាន</u>"
- ដូចមាត្រា ២៤ ៖ "<u>ដើម្បីសហការអនុវត្ត</u>"
- កាលប្បវត្តិ-ឯកសារ ។